# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣២៩ ព.ណ.ឆ.គក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុវត្តសិទ្ធិរបស់គូភាគីនៃប្រតិបត្តិការដែលមានកិច្ចធានា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ០២៣២ ពណ.បល.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនានាចំណុះឱ្យនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីការតម្កល់លិខិតជូនដំណឹង ការស្វែងរកកំណត់ត្រាសាធារណៈ ការស្នើសុំកំណត់ត្រាដែលមានការបញ្ជាក់ ការដាក់បញ្ចូលក្នុងបញ្ជីប្រុងប្រយ័ត្ន កាតព្វកិច្ចរបស់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ដើម្បីពង្រឹងយន្តការអនុវត្តសិទ្ធិរបស់គូភាគីនៃកិច្ចព្រមព្រៀងប្រាតិភោគ



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ដែលបានតម្កល់លិខិតជូនដំណឹងនៅការិយាល័យតម្កល់លិខិតជូនដំណឹង ស្របតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

**ប្រការ២ .-**

ពាក្យបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចមាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

១- ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃមាត្រា៣ និងមាត្រា៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រការនេះមានគោលបំណងបញ្ជាក់បន្ថែមឱ្យកាន់តែច្បាស់លាស់នូវប្រភេទចលនទ្រព្យទាំងឡាយដែលអាចត្រូវបានប្រើជាទ្រព្យធានាដើម្បីធានាកាតព្វកិច្ច។

២- ទ្រព្យធានាអាចជា៖

ក- **ទំនិញ** គឺជាវត្ថុដែលជាចលនវត្ថុក្នុងពេលដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ។ ក្នុងន័យនេះ **ទំនិញ** សំដៅដល់៖

- ផលិតផលរ៉ែ ដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន
- ឈើឈរដែលបម្រុងនឹងកាប់
- កូនសត្វចិញ្ចឹមគ្រប់ប្រភេទមិនទាន់កើត និង
- ផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ។

ពាក្យ **ទំនិញ** មិនរាប់បញ្ចូលនូវគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬលិខិតស្នាមឡើយ។

ខ- **កសិផល** គឺជាទំនិញរបស់កូនបំណុលដែលបានពីមុខរបរកសិកម្ម លើកលែងតែឈើឈរ។ ក្នុងន័យនេះ **កសិផល** រួមមាន៖

- ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬផលដំណាំដែលត្រូវដាំដុះ
- ទំនិញជលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម
- សត្វចិញ្ចឹមគ្រប់ប្រភេទ រាប់ទាំងកូនសត្វដែលកើតហើយ ឬមិនទាន់កើតផងដែរ
- ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិបត្តិការកសិកម្ម
- ផលដំណាំដែលប្រមូលបាន ឬផលដែលបានមកពីសត្វចិញ្ចឹមគ្រប់ប្រភេទហើយមិនទាន់កែច្នៃ
- កសិផលដែលផលិត ឬប្រមូលផលបានដោយសមាគមកសិករនៅតាមទីជនបទ ឬតាមតំបន់ទីតាំងភូមិសាស្ត្រនានា ឬ
- កសិផលផ្សេងៗទៀត ដែលត្រូវបានលើកទឹកចិត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។



82 +

គ- **ឧបករណ៍** គឺជាទំនិញទាំងឡាយ លើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តមានលេខស៊េរី។

ក្នុងន័យនេះ **ឧបករណ៍** សំដៅលើឧបករណ៍ឬរបស់របរទាំងឡាយ ដែលត្រូវប្រើប្រាស់សម្រាប់ដំណើរការអាជីវកម្ម ហើយដែលៈ

- មិនមែនសម្រាប់លក់ដូចទំនិញក្នុងឃ្លាំងសន្និធិឬស្តុក
- មិនមែនជាឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម ឬ
- មិនមែនជាឧបករណ៍សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនឬគ្រួសារឡើយ។

ឃ- **សារពើភណ្ឌ** គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬជាវត្ថុធាតុដើម គម្រោងដែលកំពុងដំណើរការ សម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម។

ក្នុងន័យនេះ **សារពើភណ្ឌ** រួមបញ្ចូលផងដែរនូវផលិតផល ស្នាដៃសិល្បៈ ឬស្នាដៃសិប្បកម្មទាំងឡាយ ដែលផលិតសម្រាប់លក់ឬជួល ដោយសហគ្រាសធុនមីក្រូ តូច និងមធ្យម ឬសមាគមអ្នកផលិតឬកែច្នៃផ្សេងៗទៀត។

ង- **យានយន្តមានលេខស៊េរី** គឺជាយានយន្ត រថសណ្តោង អាកាសយាន កាណូត ឬទូកដែលមានម៉ាស៊ីន បើយានយន្តទាំងនេះមិនមែនជាសារពើភណ្ឌរបស់កូនបំណុល។

ក្នុងន័យនេះ **យានយន្តមានលេខស៊េរី** សំដៅលើរាល់យានយន្តដែលមានម៉ាស៊ីននិងលេខសម្គាល់យានយន្ត ដែលអាចឱ្យគេកំណត់អត្តសញ្ញាណយានយន្តទាំងនោះបាន ប៉ុន្តែយានយន្តទាំងនោះមិនមែនជាសារពើភណ្ឌរបស់កូនបំណុលឡើយ។

ច- **ចលនវត្ថុតាំងភ្ជាប់** គឺជាទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬមានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ តាមរបៀបមួយដែលនាំឱ្យមានសិទ្ធិប្រត្យក្សកើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ឆ- **គណនី** គឺជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬបានជួល ឬថ្លៃសេវាកម្មនានាដែលមិនមែនជាលិខិតស្នាម ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា។

ជ- **កិច្ចសន្យាលក់ដែលមានកិច្ចធានា/ផលប័ត្រពាណិជ្ជកម្ម** គឺជាកំណត់ត្រា ដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិប្រាតិភោគលើទំនិញ ឬការជួលទំនិញ។

ឈ- **លិខិតស្នាម** គឺជាកំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬកិច្ចសន្យាជួល និងការផ្ទេរមួយប្រភេទ ដែលកើតឡើងតាមការប្រគល់ក្នុងអាជីវកម្មធម្មតា ដោយមានបិដ្ឋិលេខចំណារខ្នងឬអនុប្បទានសិទ្ធិ។ ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគផងដែរ។

ក្នុងន័យនេះ **លិខិតស្នាម** រួមបញ្ចូលទាំងភាគហ៊ុននៅក្នុងក្រុមហ៊ុនមូលធន ភាគទុននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ និង/ឬអត្ថប្រយោជន៍ផ្សេងៗទៀត ដែលម្ចាស់ហ៊ុនឬសហកម្មសិទ្ធិករមានសិទ្ធិទទួលបានពីក្រុមហ៊ុន។

ញ- **ឯកសារ** គឺជាបណ្ណកម្មសិទ្ធិឬបង្កាន់ដៃ មានជាអាទិ៍បណ្ណដឹកជញ្ជូន សក្ខីបត្រកំពង់ផែ បង្កាន់ដៃឃ្លាំង ដែលចេញដោយបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនឬស្តុកទំនិញ។

ដ- **ទំនិញដែលបានផ្ញើទុកលក់** គឺជាទំនិញទាំងឡាយដែលជាកម្មវត្ថុនៃប្រតិបត្តិការបញ្ញើទុកលក់ ដែលបុគ្គលម្នាក់ (អ្នកផ្ញើទំនិញទុកលក់) ប្រគល់ទំនិញទៅឱ្យពាណិជ្ជករ (អ្នកទទួលទំនិញទុកលក់) ដើម្បីលក់ ដោយមិនគិតពីទម្រង់នៃកិច្ចសន្យាឬពាក្យពេចន៍នៅក្នុងកិច្ចសន្យា ហើយ៖

- ពាណិជ្ជករដែលទិញនិងលក់ទំនិញប្រភេទនេះ ប្រើឈ្មោះផ្សេងពីឈ្មោះអ្នកផ្ញើទំនិញទុកលក់
- ពាណិជ្ជករមិនមែនជាអ្នកលក់ដេញថ្លៃ និង
- ទំនិញមិនមែនជាទំនិញប្រើប្រាស់មុនពេលប្រគល់ឱ្យពាណិជ្ជករ។

ឋ- **ទ្រព្យអរូបី** សំដៅសិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល និងទ្រព្យអរូបីដទៃទៀត។ ក្នុងន័យនេះ ទ្រព្យអរូបី រួមបញ្ចូលផងដែរនូវ ទ្រព្យកម្មសិទ្ធិបញ្ញា ដូចជាសិទ្ធិលើម៉ាក ពាណិជ្ជនាម និងទ្រព្យអរូបីផ្សេងទៀត ដែលត្រូវបង្កើតឡើងនិងទទួលស្គាល់ដោយច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដែលនៅជាធរមាន។

## ប្រការ៤.-

១- បុគ្គល អាចស្នើសុំតម្កល់លិខិតជូនដំណឹង នៅការិយាល័យតម្កល់លិខិតជូនដំណឹង តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម www.setfo.gov.kh ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគនិងបង្កើតសិទ្ធិអាទិភាព ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា។

២- ដើម្បីធានាបាននូវភាពជាម្ចាស់និងសុវត្ថិភាព រាល់ការស្នើសុំតម្កល់លិខិតវិសោធនកម្ម លិខិតកែតម្រូវ លិខិតសុំបន្ត ឬលិខិតសុំបញ្ចប់ បុគ្គលស្នើសុំត្រូវមានលេខសម្ងាត់ ដែលប្រព័ន្ធស្វ័យប្រវត្តិកម្មបានផ្ដល់ឱ្យនៅពេលតម្កល់លិខិតជូនដំណឹងដំបូង។ ក្នុងករណី បុគ្គលស្នើសុំមិនមានឬបាត់បង់លេខសម្ងាត់ បុគ្គលស្នើសុំអាចដាក់ពាក្យស្នើសុំលេខសម្ងាត់ពីមន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង ដោយមានបញ្ជាក់អត្តសញ្ញាណបុគ្គលស្នើសុំនិងមូលហេតុច្បាស់លាស់។

៣- បុគ្គលស្នើសុំតម្កល់លិខិតជូនដំណឹងឬលេខសម្ងាត់ ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ និងទី២ ខាងលើ ត្រូវបង់កម្រៃសេវាសាធារណៈដូចមានកំណត់នៅក្នុងប្រការ១២។

៤- បែបបទ នីតិវិធី និងឯកសារតម្រូវសម្រាប់ការស្នើសុំតម្កល់លិខិតជូនដំណឹងឬលេខសម្ងាត់ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់ក្រសួងពាណិជ្ជកម្ម។

## ប្រការ៥.-

១- រាល់ការស្នើសុំតម្កល់លិខិតជូនដំណឹង ត្រូវមានសេចក្ដីអធិប្បាយសមស្របអំពីអត្តសញ្ញាណទ្រព្យធានាទាំងឡាយ ដែលត្រូវបានប្រើដើម្បីធានាកាតព្វកិច្ចឬដែលត្រូវបានឃាត់ទុក។

២- សេចក្ដីអធិប្បាយអាចចែងជាពាក្យទូទៅបាន លើកលែងតែយានយន្តមានលេខស៊េរី។ ចំពោះយានយន្តមានលេខស៊េរី សេចក្ដីអធិប្បាយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអត្តសញ្ញាណនៃទ្រព្យធានា ដែលមានជាអាទិ៍ ពណ៌ ម៉ូដែល ស៊េរី ឆ្នាំផលិត លេខសម្គាល់យានយន្ត (លេខតួ-លេខម៉ាស៊ីន) និង/ឬលេខកូដសម្គាល់ពិសេសផ្សេងៗទៀត (ប្រសិនបើមាន)។

៣- ក្នុងករណី ទ្រព្យធានាឬទ្រព្យដែលត្រូវបានឃាត់ទុកមានចំនួនច្រើន ហើយមានលក្ខណៈស្មុគស្មាញ និងពិបាកដល់ការអធិប្បាយសមស្របនូវរាល់អត្តសញ្ញាណនៃទ្រព្យធានានីមួយៗ សេចក្តីអធិប្បាយអំពីទ្រព្យធានាទាំងនោះអាចសង្ខេបថា «ទ្រព្យសកម្មទាំងអស់របស់កូនបំណុល» ឬ «ចលនទ្រព្យទាំងអស់របស់កូនបំណុល» លើកលែងតែមានការជំទាស់ពីកូនបំណុល ឬមានការកំណត់ផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគ។

៤- គូភាគីនៃកិច្ចព្រមព្រៀងប្រាតិភោគ អាចពិចារណាលើការប្រើប្រាស់រូបថតរបស់ទ្រព្យធានា ដើម្បីដាក់បញ្ចូលជាផ្នែកឬឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងប្រាតិភោគ បន្ថែមលើសេចក្តីអធិប្បាយអំពីទ្រព្យធានា លើកលែងតែទ្រព្យធានាជាទ្រព្យអរូបីឬជាទ្រព្យដែលកើតឡើងនៅពេលអនាគត។

**ប្រការ៦ ៖**

១- ក្នុងគោលបំណងកាត់បន្ថយហានិភ័យ ព្យសនកម្ម និងវិវាទនៅពេលបង្កើតកិច្ចព្រមព្រៀងប្រាតិភោគលើចលនទ្រព្យ កិច្ចព្រមព្រៀងទិញ-លក់ កិច្ចព្រមព្រៀងបញ្ញាំ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ អនុប្បទានសិទ្ធិ និង/ឬប្រតិបត្តិការដែលមានអានុភាពលើការធានាកាតព្វកិច្ចដោយទ្រព្យធានាជាចលនទ្រព្យ បុគ្គលអាចស្នើសុំស្វែងរកកំណត់ត្រាសាធារណៈដែលដាក់តម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹង តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម www.setfo.gov.kh ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោម៖

ក- លេខតម្កល់នៃលិខិតជូនដំណឹង។

ខ- អត្តសញ្ញាណរបស់កូនបំណុល ប្រសិនបើ៖

- កូនបំណុលជារូបវន្តបុគ្គលសញ្ជាតិខ្មែរ ត្រូវប្រើលេខអត្តសញ្ញាណប័ណ្ណ
- កូនបំណុលជារូបវន្តបុគ្គលសញ្ជាតិបរទេសត្រូវប្រើលេខលិខិតឆ្លងដែនឬឈ្មោះរបស់បុគ្គលនោះ ឬ
- កូនបំណុលជានីតិបុគ្គលអាចប្រើអត្តលេខចុះបញ្ជីពាណិជ្ជកម្មឬនាមករណ៍របស់នីតិបុគ្គលនោះ។ ឬ

គ- លេខស៊េរីឬលេខសម្គាល់របស់យានយន្តមានលេខស៊េរី។

២- ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកកំណត់ត្រាសាធារណៈដែលដាក់តម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹងក្នុងការផ្តល់សេវាសាធារណៈរបស់ខ្លួន ដែលជាប់ពាក់ព័ន្ធនឹងទ្រព្យធានាស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

៣- បុគ្គលស្នើសុំត្រូវមានគណនីអ្នកប្រើប្រាស់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម www.setfo.gov.kh ដើម្បីអាចស្វែងរកកំណត់ត្រាសាធារណៈរបស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះបាន។

**ប្រការ៧ ៖**

១- បុគ្គល អាចស្នើសុំការិយាល័យតម្កល់លិខិតជូនដំណឹង ឱ្យផ្តល់កំណត់ត្រាដោយចេញលិខិតបញ្ជាក់ដែលអាចប្រើជាភស្តុតាងក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា ប្រើជាឯកសារបញ្ជាក់សម្រាប់ការស្នើសុំសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឬប្រើតាមការចាំបាច់ផ្សេងទៀត។

២- បន្ទាប់ពីទទួលបានពាក្យស្នើសុំលិខិតបញ្ជាក់ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង ត្រូវពិនិត្យផ្ទៀងផ្ទាត់កំណត់ត្រាដែលមាននៅក្នុងមូលទិន្នន័យរបស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម www.setfo.gov.kh និងចេញលិខិតបញ្ជាក់ដោយផ្អែកលើកំណត់ត្រា ដែលបានស្វែងរកឃើញត្រឹមកាលបរិច្ឆេទនិងពេលវេលាដែលបានស្នើសុំ។

៣- លិខិតបញ្ជាក់ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ អាចត្រូវបានចេញជូនក្នុងទម្រង់ជាលិខិតស្នាមដែលបោះពុម្ពចេញឬទម្រង់អេឡិចត្រូនិកដោយមានត្រារបស់ក្រសួងពាណិជ្ជកម្ម។

៤- បុគ្គលស្នើសុំលិខិតបញ្ជាក់ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវបង់កម្រៃសេវាសាធារណៈដូចមានកំណត់នៅក្នុងប្រការ១២។

៥- បែបបទ នីតិវិធី និងឯកសារតម្រូវសម្រាប់ការស្នើសុំលិខិតបញ្ជាក់ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៨ _**

១- ជាទូទៅ ម្ចាស់បំណុលនិងកូនបំណុលនៃកិច្ចព្រមព្រៀងប្រាតិភោគឬប្រតិបត្តិការដែលមានកិច្ចធានា មានសេរីភាពក្នុងការកំណត់ពីស្ថានភាពឬលក្ខខណ្ឌនៃការមិនសងបំណុលឬការខកខានមិនបានអនុវត្តកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងរបស់ខ្លួន។

២- នៅពេលដែលកូនបំណុលមិនសងបំណុលឬខកខានមិនបានអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ អាចស្នើសុំឱ្យមន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹងពិនិត្យនិងផ្ទៀងផ្ទាត់ដាក់បញ្ចូលកូនបំណុលនោះក្នុងបញ្ជីប្រុងប្រយ័ត្ន។

៣- រាល់ការស្នើសុំដូចមានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើ ម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ ត្រូវភ្ជាប់ជាមួយនូវ៖

ក- សំអាងហេតុ។

ខ- អត្តសញ្ញាណនៃកូនបំណុលនិងទ្រព្យធានា។

គ- លិខិតបញ្ជាក់ដូចមានកំណត់នៅក្នុងប្រការ៧។

ឃ- ភស្តុតាងគាំទ្រផ្សេងទៀត។ និង

ង- លិខិតធានាអះអាងរបស់ម្ចាស់បំណុល។

៤- បន្ទាប់ពីទទួលបានការស្នើសុំ ព្រមជាមួយឯកសារនិងភស្តុតាងដូចមានកំណត់នៅក្នុងកថាខណ្ឌទី៣ ខាងលើ មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ សម្រេច និងធ្វើបច្ចុប្បន្នភាពបញ្ជីប្រុងប្រយ័ត្នយ៉ាងទៀងទាត់ ព្រមទាំងបញ្ជូនបញ្ជីដែលបានធ្វើបច្ចុប្បន្នភាពនោះទៅគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម។

៥- ក្នុងករណីនីតិបុគ្គលណាមួយត្រូវបានដាក់បញ្ចូលក្នុងបញ្ជីប្រុងប្រយ័ត្ន មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង ត្រូវរៀបចំដាក់បញ្ចូលជាឧបសម្ព័ន្ធផងដែរ នូវបញ្ជីឈ្មោះម្ចាស់ហ៊ុននិង/ឬសមាជិកក្រុមប្រឹក្សាភិបាលរបស់នីតិបុគ្គលនោះ ដែលមានជាប់ឈ្មោះជាកូនបំណុល។

៦- បញ្ជីប្រុងប្រយ័ត្ននិងឧបសម្ព័ន្ធ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឬបញ្ជូនទៅបុគ្គលណាមួយដែលគ្មានភារកិច្ចក្នុងការពិនិត្យនិងផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មឡើយ។

៧- បុគ្គល អាចស្នើសុំការិយាល័យតម្កល់លិខិតជូនដំណឹងឱ្យផ្តល់នូវលិខិតបញ្ជាក់ពីស្ថានភាពរបស់ខ្លួនផ្ទាល់ថាកំពុងមានឬគ្មានឈ្មោះនៅក្នុងបញ្ជីប្រុងប្រយ័ត្ននៃក្រសួងពាណិជ្ជកម្ម។

៨- បុគ្គលស្នើសុំដាក់បញ្ចូលកូនបំណុលក្នុងបញ្ជីប្រុងប្រយ័ត្ន និង/ឬ លិខិតបញ្ជាក់ពីស្ថានភាពរបស់ខ្លួនផ្ទាល់ថាកំពុងមានឬគ្មានឈ្មោះនៅក្នុងបញ្ជីប្រុងប្រយ័ត្ន ត្រូវបង់កម្រៃសេវាសាធារណៈដូចមានកំណត់នៅក្នុងប្រការ១២។

៩- បែបបទ នីតិវិធី និងឯកសារតម្រូវសម្រាប់ការស្នើសុំដាក់បញ្ចូលកូនបំណុលនោះក្នុងបញ្ជីប្រុងប្រយ័ត្ន និង/ឬលិខិតបញ្ជាក់ពីស្ថានភាព ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៩ _**

១- កូនបំណុលត្រូវបានដកឈ្មោះឬនាមករណ៍ចេញពីបញ្ជីប្រុងប្រយ័ត្ននិង/ឬឧបសម្ព័ន្ធ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- មានការតម្កល់លិខិតសុំបញ្ចប់។

ខ- កូនបំណុលនោះលែងជាកូនបំណុលក្នុងលិខិតជូនដំណឹង។

គ- មានការស្នើសុំពីម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ។

ឃ- មានការប្តឹងតវ៉ាពីកូនបំណុល ដែលមានអំណះអំណាងនិងភស្តុតាងបញ្ជាក់គ្រប់គ្រាន់។

ង- មានកិច្ចព្រមព្រៀងសះជាឬកិច្ចព្រមព្រៀងបញ្ចប់វិវាទ។ ឬ

ច- មរណភាពកូនបំណុល។

២- ក្នុងរយៈពេល ៣ (បី) ថ្ងៃ នៃថ្ងៃធ្វើការ ម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារមានកាតព្វកិច្ចស្នើសុំដកឈ្មោះឬនាមករណ៍កូនបំណុលចេញពីបញ្ជីប្រុងប្រយ័ត្ននិង/ឬឧបសម្ព័ន្ធ ក្នុងករណីដែលកូនបំណុលនោះបានបំពេញកាតព្វកិច្ចឬបានទូទាត់សងបំណុលរួចរាល់។ ក្នុងករណី ម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ ខកខានមិនបានអនុវត្តកាតព្វកិច្ចខាងលើ កូនបំណុលមានសិទ្ធិស្នើសុំការិយាល័យតម្កល់លិខិតជូនដំណឹងឱ្យដកឈ្មោះឬនាមករណ៍ចេញពីបញ្ជីប្រុងប្រយ័ត្ននិង/ឬឧបសម្ព័ន្ធ ដោយបង្ហាញនូវអំណះអំណាងនិងភស្តុតាងបញ្ជាក់គ្រប់គ្រាន់។

៣- ម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាតទាំងឡាយរបស់កូនបំណុល ដែលកើតឡើងពីការខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ។

៤- បុគ្គលស្នើសុំដកឈ្មោះឬនាមករណ៍ចេញពីបញ្ជីប្រុងប្រយ័ត្ននិង/ឬឧបសម្ព័ន្ធ ត្រូវបង់កម្រៃសេវាសាធារណៈដូចមានកំណត់នៅក្នុងប្រការ១២។

៥- បែបបទ នីតិវិធី និងឯកសារតម្រូវសម្រាប់ការស្នើសុំដកឈ្មោះឬនាមករណ៍ចេញពីបញ្ជីប្រុងប្រយ័ត្ននិង/ឬឧបសម្ព័ន្ធ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ១០ ._**

១- ក្នុងគោលដៅជានាឱ្យការតម្កល់លិខិតជូនដំណឹងប្រព្រឹត្តទៅបានប្រកបដោយ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព និងតម្លាភាព មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង មានអំណាចលើរាល់កិច្ចការរដ្ឋបាលទាំងឡាយ ដូចបានបញ្ញត្តនៅក្នុងជំពូកទី៣ (ការតម្កល់លិខិតជូនដំណឹង) នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និង ប្រកាសលេខ ០២៣២ ពណ.បល.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនានាចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស។

២- អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤០ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង មានសិទ្ធិអំណាចក្នុងការបដិសេធការតម្កល់លិខិតជូនដំណឹងនៅក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលលិខិតជូនដំណឹង ប្រសិនបើរកឃើញថា៖

ក- លិខិតជូនដំណឹងដំបូងមិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ។

ខ- វិសោធនកម្មមិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវឬវិសោធនកម្មបញ្ជាក់ពីលិខិតជូនដំណឹងដំបូងដែលផុតរយៈពេលមានប្រសិទ្ធភាព។

គ- លិខិតសុំបន្តមិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ឬមិនបានប្រគល់ជូនក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ដែលច្បាប់បានអនុញ្ញាត។ ឬ

ឃ- លិខិតសុំបញ្ចប់មិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ឬមិនមានការអនុញ្ញាតពីម្ចាស់បំណុលក្នុងលិខិតជូនដំណឹងឬតំណាង/ភ្នាក់ងារ។

៣- ក្នុងករណីមន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង បដិសេធទទួលការតម្កល់លិខិតជូនដំណឹង ការិយាល័យតម្កល់លិខិតជូនដំណឹង ត្រូវបញ្ជូនអង្គហេតុ និងមូលហេតុនៃការបដិសេធរបស់ខ្លួនទៅបុគ្គលស្នើសុំ។ ប្រសិនបើ មិនមានមូលហេតុណាមួយដែលនាំឱ្យមានការបដិសេធទទួលការតម្កល់លិខិតជូនដំណឹង មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹង ត្រូវចេញលិខិតបញ្ជាក់ទទួលការតម្កល់ក្នុងទម្រង់អេឡិចត្រូនិកដល់បុគ្គលស្នើសុំ។

៤- មន្ត្រីការិយាល័យតម្កល់លិខិតជូនដំណឹងមានសិទ្ធិអំណាចពិនិត្យ ផ្ទៀងផ្ទាត់ សម្រេច និងធ្វើបច្ចុប្បន្នភាពបញ្ជីប្រុងប្រយ័ត្ន ដូចមានកំណត់ក្នុងប្រការ៨។

**ប្រការ១១ ._**

១- គ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម អាចស្វែងរកកំណត់ត្រាសាធារណៈដែលដាក់តម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹង ដូចមានកំណត់ក្នុងប្រការ៦ តាមការពាក់ព័ន្ធរបស់សាមីអង្គភាពនីមួយៗមុនពេលផ្តល់សេវាសាធារណៈដល់បុគ្គលស្នើសុំ។

២- គ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចត្រូវពិនិត្យផ្ទៀងផ្ទាត់បញ្ជីប្រុងប្រយ័ត្ន ដូចមានកំណត់នៅក្នុងប្រការ៨ មុនពេលផ្តល់សេវាសាធារណៈដល់បុគ្គលស្នើសុំ។

៣- អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទប់ស្កាត់ ផ្អាក ឬបដិសេធផ្តល់សេវាសាធារណៈចំពោះកូនបំណុលដែលមាននៅក្នុងកំណត់ត្រាបញ្ជីប្រុងប្រយ័ត្ន រហូតដល់ពេលដែលកូនបំណុលនោះត្រូវបានដកចេញពីបញ្ជីប្រុងប្រយ័ត្ន។

៤- បញ្ញត្តិនៃកថាខណ្ឌទី៣ ខាងលើ អនុវត្តតែចំពោះរាល់កូនបំណុលនិង/ឬទ្រព្យធានាដែលស្ថិតនៅក្រោមវិសាលភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មប៉ុណ្ណោះ។

**ប្រការ១២ .-**

រាល់កម្រៃសេវាដែលពាក់ព័ន្ធនឹងការស្នើសុំទាំងឡាយដែលកំណត់ដោយប្រកាសនេះ ត្រូវបង់ចូលជាថវិការដ្ឋ ដោយអនុលោមតាមប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ១៣ .-**

ប្រកាសនិងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## នៃប្រកាសលេខ ៣១៩៣៣.សតក.ប្រក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០២៣

## និយមន័យ

ពាក្យបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា** សំដៅដល់ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧។

២- **ប្រតិបត្តិការដែលមានកិច្ចធានា** សំដៅដល់រាល់ប្រតិបត្តិការដែលមានអានុភាពលើការធានាកាតព្វកិច្ច ដោយទ្រព្យធានាដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា រួមមាន ការបញ្ចាំចលនវត្ថុ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ អនុប្បទានសិទ្ធិ ជាដើម។

៣- **សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម** សំដៅដល់កម្រងសេវាសាធារណៈរបស់ក្រសួង ពាណិជ្ជកម្ម ដូចមានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ដែលនៅជាធរមាន។

៤- **អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម** សំដៅដល់គ្រប់អង្គភាពនៃក្រសួងពាណិជ្ជកម្ម ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គភាពក្រៅប្រទេស និងសហគ្រាសសាធារណៈ ដូចមានចែងក្នុងអនុក្រឹត្យ លេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម។

៥- **ទ្រព្យធានា** សំដៅដល់ទ្រព្យធានាដែលជាចលនទ្រព្យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ហើយត្រូវបានបញ្ជាក់ឱ្យកាន់តែច្បាស់លាស់បន្ថែមដោយប្រការ ៣ ខាងលើ។

៦- **លិខិតជូនដំណឹង** សំដៅដល់កំណត់ត្រាដែលបានតម្កល់ឬដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹង ដោយរាប់បញ្ចូលទាំងលិខិតជូនដំណឹងដំបូង លិខិតវិសោធនកម្ម លិខិតកែតម្រូវ លិខិតសុំបន្ត និងលិខិតសុំបញ្ចប់ ដែលបានតម្កល់ឬដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹង។ ក្នុងគោលបំណងរបស់ប្រកាសនេះ ពាក្យ លិខិតជូនដំណឹង ត្រូវបានប្រើសម្រាប់សម្គាល់នូវ៖

ក- លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាជាចលនទ្រព្យ។ ឬ

ខ- លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកៈនៃសិទ្ធិឃាត់ទុក។

៧- **ការិយាល័យតម្កល់លិខិតជូនដំណឹង** សំដៅដល់ការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា នៅក្នុងនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ក្រសួងពាណិជ្ជកម្ម ដែលត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ ០២៣២ ពណ.បល.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនានាចំណុះឱ្យនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស។

៨-   **បុគ្គលស្នើសុំ** សំដៅដល់បុគ្គលដែលស្នើសុំសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

៩-   **បុគ្គល** សំដៅដល់រូបវន្តបុគ្គល និងនីតិបុគ្គល ។